## រឿងទី១១៖ កូនពៅវង្វេង

**ខគម្ពីរ៖**
**លូកា១៥៖៣២**

យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះ រស់ឡើងវិញហើយ។
វាបានវង្វេងបាត់ តែឥឡូវនេះ យើងរកឃើញវិញហើយ៉ៈ។

កាលពីយូរលង់មកហើយ នៅក្នុងភូមិមួយមានបុរសម្នាក់ និងកូនប្រុសពីរនាក់។
បុរសនោះស្រឡាញ់កូនប្រុសទាំងពីររបស់គាត់ខ្លាំងណាស់។
ក្នុងចំណោមកូនទាំងពីរ កូនច្បងជាកូនដែលស្តាប់បង្គាប់ឪពុក។
ប៉ុន្តែកូនប្រុសពៅជាកូនដែលចូលចិត្តតែការលេងសប្បាយ។
មានថ្ងៃមួយ កូនពៅបានគិតថាចង់ចាកចេញពីផ្ទះ ទៅរស់នៅដោយខ្លួនឯង។
គឺដោយសារតែគាត់គិតថា បើសិនជាចាកចេញពីផ្ទះ នោះគាត់អាចធ្វើអ្វីបានតាមចិត្ត។
កូនពៅបាននិយាយទៅកាន់ឪពុកថា៖ «លោកឪពុក! សូមចែកកេរមរតកឱ្យកូនមក! កូនចង់ចាកចេញពីផ្ទះ ទៅរស់នៅដោយខ្លួនឯង!
ឪពុកពិបាកចិត្តដោយព្រោះកូនចាកចេញទៅ ប៉ុន្តែគាត់បានចែកកេរមត៌កឱ្យតាមអ្វីដែលគាត់សុំ។
កូនពៅបានទទួលកេរមរតកហើយ ក៏បានចាកចេញទៅ។ គាត់បានធ្វើដំណើរទៅដល់ស្រុកមួយធំស្រស់ឆើតឆាយ គាត់បានហៅមិត្តភក្តិថ្មី
បរិភោគអាហារឆ្ងាញ់ៗ ផឹកស្រាទំពាំងបាយជូរថ្លៃៗ។
ហើយទិញត្បូង សំលៀកបំពាក់ថ្លៃៗប្រៀបនឹងស្តេច វាបានចាយវាយប្រាក់យ៉ាងខ្ជះខ្ជាយ។
ទីបំផុត កូនពៅក៏បានចាយវាយទ្រព្យសម្បត្តិដែលបានពីឪពុកអស់ទៅ។
នៅពេលដែលអស់ទ្រព្យសម្បត្តិ មិត្តភក្តិក៏បានចាកចេញពីគាត់។ កូនពៅធ្លាក់ខ្លួនគោកយ៉ាក និងឯកោ។
កូនពៅមិនអាចអត់ទ្រាំនឹងភាពស្រេកឃ្លានបាន ក៏ចូលទៅធ្វើជាអ្នកបម្រើនៅក្នុងផ្ទះមួយ។
កូនពៅពិបាក និងសោកសៅណាស់។ ពេលនោះ គាត់បាននឹកឃើញដល់ឪពុក។
គាត់ចង់ត្រឡប់ទៅកាន់ឪពុករបស់គាត់វិញ។
ដូច្នេះ កូនពៅក៏បានត្រឡប់ទៅស្រុកកំណើតវិញ។
នៅពេលដែលទៅកាន់តែជិតដល់ផ្ទះរបស់ឪពុកគាត់ គាត់បារម្ភ និងភ័យព្រួយ។





កូនពៅដើរបណ្ដើរ យំបណ្ដើរ ដើរឆ្ពោះសំដៅទៅផ្ទះឪពុក។
ប៉ុន្តែ ឪពុកបានឃើញកូនពៅពីចម្ងាយ។
ឪពុកតែងតែឈរនៅមុខទ្វារជារៀងរាល់ថ្ងៃ រង់ចាំរហូតកូនពៅត្រឡប់មកវិញ។
ពេលដែលឃើញកូនពៅភ្លាម ឪពុកបានស្ទុះទៅឱបកូន។
ឪពុកប្រាប់ទៅកាន់ពួកអ្នកបម្រើថា៖ «ចូរទៅយកសំលៀកបំពាក់ល្អៗបំផុត មកពាក់ឱ្យកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើង មកពាក់ឱ្យផង។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងឱ្យសប្បាយចុះ!»
ឪពុករីករាយណាស់ ហើយបានធ្វើពិធីជប់លៀងយ៉ាងធំ។
ចុងក្រោយ កូនពៅក៏បានយល់អំពីក្ដីស្រឡាញ់ដ៏ធំធេងរបស់ឪពុក។

- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា១៥៖៣២)

វាបានវង្វេងបាត់ តែឥឡូវនេះ យើងរកឃើញវិញហើយ





**សកម្មភាពទី១** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



**សកម្មភាពទី២** សូមកាត់រូបភាពខាងក្រោម ហើយបិទភ្ជាប់ទៅតាមលំដាប់លំដោយនៃមេរៀនដែលបានរៀននៅថ្ងៃនេះ។

| | | |
|---|---|---|
| 1 | 2 | 3 |
| 4 | 5 | 6 |


















KIDS GOD WORSHIP
www.kidsworship.kr

Selah
Ministry of Christian Publishing

ឈ្មោះ: